ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
គណៈកម្មាធិការលទ្ធកម្ម
លេខ :..០៨៧....បទ.គល

ថ្ងៃ សុក្រ ១៥កើត ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ ជួសជុល ផ្លាស់ប្តូរ និងកែសម្រួលឧបករណ៍បច្ចេកទេសដើម្បីភ្ជាប់ទៅកាន់មាត់ច្រកអ៊ិនធឺណិត នៅមជ្ឈមណ្ឌលទិន្នន័យ អគារមិត្តភាព ទីស្តីការគណៈរដ្ឋមន្ត្រី

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សូមជូនដំណឹងចំពោះក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកតបុគ្គល)ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការជួសជុល ផ្លាស់ប្តូរ និងកែសម្រួលឧបករណ៍បច្ចេកទេសដើម្បីភ្ជាប់ទៅកាន់មាត់ច្រកអ៊ិនធឺណិតនៅមជ្ឈមណ្ឌលទិន្នន័យ អគារមិត្តភាព ទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលមានអាសយដ្ឋានអគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី..០២...ខែមីនា...ឆ្នាំ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ( ទូរសព្ទទាក់ទងលេខ ០២៣ ៤២៧ ៥០៧)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃនៅវេលាម៉ោង១៥:០០រសៀល ថ្ងៃទី..១៨...ខែមីនា...ឆ្នាំ២០១៨។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាសយដ្ឋានខាងលើ វេលាម៉ោង ..១៥:០០..រសៀល ថ្ងៃទី..១៨...ខែមីនា...ឆ្នាំ២០១៨។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់ឯកសារដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានបន្ថែមដែលទាក់ទងនឹងការដេញថ្លៃនេះ។

ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម
អនុប្រធានទី១

សារ៉ាត់ ខាន់

ចម្លងជូន :
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ឯកសារ កាលប្បវត្តិ